# គណបក្ស សិទ្ធិមនុស្ស

**HUMAN RIGHTS PARTY**

បំរើ ការពារ កសាង

លេខ០១៥៥...គ.ស.ម
/០៩

ភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩

## សេចក្ដីថ្លែងការណ៍

## " អ្នកតំណាងរាស្ត្រ មួរ សុខហួរ មិនគួរបង់ប្រាក់ឡើយ "

**គណបក្សសិទ្ធិមនុស្ស (គ.ស.ម.)** សូមសម្ដែងនូវការខកចិត្តយ៉ាងខ្លាំង និងមិនគាំទ្រនូវរាល់ការសម្រេចទាំងឡាយណាដែលតម្រូវឱ្យអ្នកតំណាងរាស្ត្រ **មួរ សុខហួរ** បង់ប្រាក់ដោយអយុត្តិធមិដែលសាលក្រមរបស់តុលាការរាជធានីភ្នំពេញបានប្រកាសនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ នោះឡើយ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា អ្នកតំណាងរាស្ត្រ **មួរ សុខហួរ** មិនបានប្រព្រឹត្តិអ្វីខុសច្បាប់ឡើយ ផ្ទុយទៅវិញគាត់គឺជាឥស្សរៈជនរងគ្រោះ ដែលគួរតែទទួលបានយុត្តិធមិ ។ ក៏ប៉ុន្តែរាល់ការសម្រេចឱ្យគាត់បង់ប្រាក់ដោយអយុត្តិធមិ និងដោយមិនមានឱកាសគ្រប់គ្រាន់ក្នុងការការពារឱ្យបានស្ថិតស្ថាញលដល់ទីបញ្ចប់នោះ ។ **គ.ស.ម.** យល់ឃើញថា អាចជាការលើកមុខមាត់ឱ្យអ្នកមានអំណាចបន្តការកៀបសង្កត់ គំរាមកំហែងយ៉ាងងាយស្រួលតទៅទៀត ក៏ដូចជាការកាច់បំបាក់ស្មារតីអ្នកតស៊ូដើម្បីសេរីភាពឱ្យខ្លាចរអាដូច្នោះដែរ ។

**គណបក្សសិទ្ធិមនុស្ស** គាំទ្រ និងលើកទឹកចិត្តដល់អ្នកតំណាងរាស្ត្រ **មួរ សុខហួរ** ឱ្យបន្តធ្វើការតស៊ូដោយអហិង្សាតទៅទៀតដើម្បីសេរីភាព និងយុត្តិធមិដោយអង់អាចក្លាហានក្នុងភាពជាស្ត្រីគំរូ ជាអ្នកតំណាងរាស្ត្រឈានមុខ ជាអ្នកផ្ដល់ភាពកក់ក្ដៅដល់អ្នកទន់ខ្សោយ ដែលរងគ្រោះដោយអំពើផ្ដាច់ការផ្សេងៗទៀត ។ ៥

គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

**ពត៌មានបន្ថែមសូមទាក់ទង :**

លេខទូរស័ព្ទ : ០១៦ ៤៣៥ ១០៦

Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com | Website: www.hrpcambodia.info